ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំ ឆ្នាំ២០២៤ និងទិសដៅការងារ ឆ្នាំ២០២៥ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃសៅរ៍ ១១កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៥

**សូមគោរព៖**

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយជាអនេក និងសូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ធនាគារជាតិនៃកម្ពុជា។ នៅឆ្នាំនេះ ជាលើកទី១ហើយ ដែលបុគ្គលិកយើងទាំងអស់បានជួបជុំគ្នា សរុបចំនួនប្រមាណ ២០០០ រូប ដែលផ្តល់ឱកាសឱ្យយើងបានបង្កើនទំនាក់ទំនង ជាពិសេសយល់ជ្រួតជ្រាបពីខ្លឹមសារនៃអង្គសន្និបាតនាថ្ងៃនេះ។

សន្និបាតរបស់យើងត្រូវបានរៀបចំឡើង បន្ទាប់ពីប្រជាជនកម្ពុជាទូទាំងប្រទេសបានប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤៦ នៃទិវាជ័យជម្នះ ៧ មករា (៧ មករា ១៩៧៩ - ៧ មករា ២០២៥) និងខួបលើកទី២៦ នៃទិវានយោបាយឈ្នះ-ឈ្នះ (២៩ ធ្នូ ១៩៩៨ - ២៩ ធ្នូ ២០២៤) ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា សម្រេចបានក្នុងការបញ្ចប់សង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ និងបាននាំមកនូវសន្តិភាពពេញលេញ ជាប្រវត្តិសាស្ត្រនៅកម្ពុជា។ ក្រោមការបន្តដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យ ត្រូវបានសម្រេចដោយជោគជ័យ ក្នុងស្ថានភាពដែលពិភពលោកបាននិងកំពុងប្រឈមនឹងភាពមិនច្បាស់លាស់



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

កាន់តែច្រើន ជាពិសេសការអូសបន្លាយសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន ជម្លោះប្រដាប់អាវុធនៅមជ្ឈិមបូព៌ា ក៏ដូចជាអស្ថិរភាពនយោបាយនៅប្រទេសមួយចំនួន។

នៅឆ្នាំ២០២៤ សេដ្ឋកិច្ចពិភពលោកត្រូវបានវាយតម្លៃថាមានភាពធន់ដោយសម្រេចបានអត្រាកំណើនទាបជាងឆ្នាំ២០២៣បន្តិច បើទោះបីជាប្រឈមនឹងឧបសគ្គជាច្រើនក៏ដោយ។ នៅប្រទេសចិន វិបត្តិអចលនទ្រព្យនិងការធ្លាក់ចុះនៃតម្រូវការក្នុងស្រុក ព្រមទាំងបញ្ហាដក់សល់ពីវិបត្តិកូវីដ-១៩បានធ្វើឱ្យសេដ្ឋកិច្ចបន្តកើនឡើងក្នុងល្បឿនយឺត។ ទន្ទឹមនេះ សហភាពអឺរ៉ុបនិងបណ្តាប្រទេសមួយចំនួនបន្តមានកំណើនសេដ្ឋកិច្ចទាប ដោយរងឥទ្ធិពលដោយផ្ទាល់និង/ឬប្រយោលពីសង្គ្រាម អស្ថិរភាពនយោបាយ និងអត្រាការប្រាក់ខ្ពស់។ ដោយឡែក សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានកំណើនល្អ ដោយសារប្រជាជនក្នុងស្រុកមានតម្រូវការប្រើប្រាស់ច្រើន និងមានការងារធ្វើច្រើនជាងមុន។

ជាមួយនឹងការរក្សាបានកំណើនសេដ្ឋកិច្ច ពិភពលោកក៏សម្រេចបានជោគជ័យក្នុងការកាត់បន្ថយអត្រាអតិផរណាជាបន្តបន្ទាប់ពី ៨,៦% នៅឆ្នាំ២០២២ មក ៥,៧% នាឆ្នាំ២០២៤ ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៍ ដែលអត្រាអតិផរណាបានថយចុះដល់ ២,៦% ដោយសារការរក្សាអត្រាការប្រាក់គោលឱ្យនៅខ្ពស់ គួបផ្សំនឹងការធ្លាក់ថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារ។ ការថយចុះនៃអតិផរណាបានផ្តល់លទ្ធភាពឱ្យធនាគារកណ្តាលធំៗ កាត់បន្ថយអត្រាការប្រាក់គោលសន្សឹមៗ ចាប់ពីឆមាសទី២ ឆ្នាំ២០២៤ មក។

នៅកម្ពុជា ការអនុវត្តដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ បានជួយជំរុញសេដ្ឋកិច្ចឱ្យបន្តងើបឡើង ក្នុងអត្រា ៦% នាឆ្នាំ២០២៤។ កម្រិតកំណើននេះគាំទ្រជាចម្បងដោយកំណើនខ្ពស់នៃការនាំចេញ ជាពិសេសផលិតផលកាត់ដេរ និងការបន្តងើបឡើងជាលំដាប់នៃវិស័យទេសចរណ៍ ទោះបីវិស័យសំណង់និងអចលនទ្រព្យ និងកសិកម្មបន្តមានកំណើនទាបក៏ដោយ។

ទន្ទឹមនេះ អតិផរណាជាមធ្យមមានកម្រិតត្រឹម ០,៨% នាឆ្នាំ២០២៤ ដោយសារការធ្លាក់ថ្លៃប្រេងឥន្ធនៈ ម្ហូបអាហារ ស្របពេលដែលទំនិញនិងសេវាផ្សេងៗទៀតឡើងថ្លៃយឺត។ លើសពីនេះ ការរក្សាបានស្ថិរភាពតម្លៃប្រាក់រៀលក៏បានរួមចំណែកក្នុងការរក្សាស្ថិរភាពថ្លៃទំនិញ និងសេវាទូទៅលើទីផ្សារផងដែរ។ អត្រាប្តូរប្រាក់មានកម្រិតជាមធ្យម ៤.០៧១ រៀលក្នុងមួយដុល្លារអាមេរិក ដោយបានឡើងថ្លៃប្រមាណ ០,៩% ធៀបនឹងឆ្នាំ២០២៣ ដែលធ្វើឱ្យអត្រាប្តូរប្រាក់វិលទៅរកកម្រិតមុនវិបត្តិកូវីដ-១៩ វិញ។ "*កម្រិតទាបនៃអតិផរណា បានបង្ហាញថាធនាគារជាតិនៃកម្ពុជា សម្រេចបាននូវបេសកកម្មចម្បងរបស់ខ្លួនក្នុងការអនុវត្តនយោបាយរូបិយវត្ថុ ស្របតាមក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល*"។ អត្រាអតិផរណាទាបនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការជួយរក្សាកម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

លើសពីនេះ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងការគ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយប្រសិទ្ធភាព បានរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិ ដល់ ២២,៥ ប៊ីលានដុល្លារអាមេរិក ពោលគឺកើនឡើង ១២,៦% ធៀបនឹងឆ្នាំ២០២៣។ កម្រិតទុនបម្រុងអន្តរជាតិរបស់កម្ពុជាត្រូវបានបន្តចាត់ទុកថាមានកម្រិតខ្ពស់សមស្រប ដែលស្មើនឹងប្រមាណ ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់។

ចំពោះប្រព័ន្ធធនាគារ ឥណទាននៅតែបន្តកើនឡើង តែក្នុងល្បឿនយឺតជាងមុន។ ការថមថយនេះ គឺដោយសារកត្តាតម្រូវការនិងផ្គត់ផ្គង់។ ចំពោះកត្តាតម្រូវការ គឺដោយសារការងើបឡើងយឺតនៃវិស័យមួយចំនួនដូចជា វិស័យសំណង់និងអចលនទ្រព្យ ទេសចរណ៍ និងលក់ដុំនិងរាយ ដែលនាំឱ្យអតិថិជនកាត់បន្ថយការខ្ចី ហើយចំពោះកត្តាផ្គត់ផ្គង់ គឺដោយសារគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនការប្រុងប្រយ័ត្នក្នុងការផ្តល់ឥណទាន ក្នុងស្ថានភាពដែលសេដ្ឋកិច្ចតំបន់និងពិភពលោកមានភាពមិនប្រាកដប្រជាខ្ពស់។ យ៉ាងណាមិញ ប្រាក់បញ្ញើបានបន្តកើនឡើងល្អ ដោយមានអត្រាកំណើន ១៦,៣% ជាមួយនឹងស្ថានភាពរឹងមាំនៃដើមទុន និងលទ្ធភាពបញ្ចេញសាច់ប្រាក់មានកម្រិតខ្ពស់ ដែលបង្ហាញថា ប្រព័ន្ធធនាគារមានភាពធន់ជាមួយនឹងជំនឿទុកចិត្តរឹងមាំ។

ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ច ជាពិសេសការជួយសម្រាលបន្ទុករបស់អាជីវករ និងប្រជាជនដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបន្តអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពិភាក្សាជាមួយអតិថិជនលើការកែប្រែលក្ខខណ្ឌសងត្រឡប់កម្ចី។ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព បទប្បញ្ញត្តិមួយចំនួនត្រូវបានបន្តបន្ធូរបន្ថយ ខណៈដែលការធានាបាននូវស្ថិរភាពប្រព័ន្ធធនាគារនៅបន្តជាអាទិភាពចម្បង ដូចជាការរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងកម្រិតទាបត្រឹម ៧% និងការអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនត្រឹម ១,២៥% រហូតដល់ចុងឆ្នាំ២០២៥ ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសាច់ប្រាក់កាន់តែច្រើនក្នុងការផ្តល់កម្ចីបន្តទៅអតិថិជន។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជា ក៏បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការពង្រឹងការតាមដាន និងជួយគាំទ្រដល់វិស័យអចលនទ្រព្យ ទេសចរណ៍និងកសិកម្ម ក៏ដូចជាការពង្រឹងការយល់ដឹងរបស់សាធារណជនលើបញ្ហាហិរញ្ញវត្ថុ ជាពិសេសបញ្ហាប្រឈមទាក់ទងនឹងការផ្សព្វផ្សាយកាន់តែច្រើនអំពីកម្ចីអនឡាញខុសច្បាប់របស់ជនឆបោក ដែលអាចបង្កគ្រោះថ្នាក់ដល់សង្គម និងសេដ្ឋកិច្ចគ្រួសារ។

គួររំលឹកផងដែរថា ថ្មីៗនេះយើងក៏បានសង្កេតឃើញថាមានសកម្មភាពផ្សព្វផ្សាយ និងផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ ជាពិសេសសេវាឥណទាន តាមរយៈទូរសព្ទ និងបណ្តាញសង្គមនានា ក៏ដូចជាមានការបន្លំខ្លួនជាមន្ត្រីរាជការ ឬគណនីផ្លូវការរបស់ក្រសួង-ស្ថាប័ន។ សកម្មភាពទាំងនេះបានធ្វើឱ្យសាធារណជនមានការភាន់ច្រឡំ និងបានបង្កផលវិបាកជាច្រើន

មកលើសង្គម តាមរយៈការយកអត្រាការប្រាក់ខ្ពស់ហួសហេតុ ការអនុវត្តកិច្ចសន្យាមិនសុចរិត កេងចំណេញហួសហេតុពីអ្នកខ្ចីប្រាក់ និងការគំរាមកំហែងបំភិតបំភ័យ ដែលបានបណ្តាលឱ្យប្រជាជនរងគ្រោះ និងធ្លាក់ក្នុងបំណុលវ័ណ្ឌក។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

បច្ចុប្បន្ន បច្ចេកវិទ្យាមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅគ្រប់វិស័យ។ ស្របតាមនវានុវត្តន៍បច្ចេកវិទ្យា និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ចនិងសង្គមឌីជីថល ប្រព័ន្ធទូទាត់សងប្រាក់ទាំងតម្លៃរាយនិងតម្លៃធំត្រូវបានធ្វើទំនើបកម្មជាលំដាប់ ហើយត្រូវបានទទួលស្គាល់ដោយមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ក្នុងការផ្តល់ភាពងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាព ព្រមទាំងបានរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនិងបរិយាបន្នហិរញ្ញវត្ថុ។ ប្រព័ន្ធបាគងត្រូវបានតភ្ជាប់ជាមួយបណ្តាប្រទេសជាច្រើនក្នុងតំបន់ និងក្រុមហ៊ុនបណ្តាញទូទាត់អន្តរជាតិនានា ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការបង់ប្រាក់តាមយូអរកូតនៅប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េខាងត្បូង និងប្រើប្រាស់ជាមួយក្រុមហ៊ុនយូញៀនផេ និងអាលីផេ។ ការណ៍នេះបានសម្រួលដល់ការធ្វើពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ក៏ដូចជាការជំរុញការប្រើប្រាស់ប្រាក់រៀលផងដែរ។

ម៉្យាងទៀត កម្មវិធីទូទាត់បាគងទេសចរត្រូវបានដាក់ឱ្យដំណើរការ និងបានសហការជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ Mastercard និង Visa ដើម្បីរួមចំណែកលើកកម្ពស់វិស័យទេសចរណ៍ ដោយអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិអាចធ្វើប្រតិបត្តិការទូទាត់ទំនិញនិងសេវាតាមយូអរកូតបានយ៉ាងទូលំទូលាយ។ សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងពីការរួមចំណែករបស់ធនាគារជាតិនៃកម្ពុជា ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់រាជរដ្ឋាភិបាល តាមរយៈការលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបើកគណនី និងផ្តល់សេវាទូទាត់សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក៏ដូចជាអ្នកប្រកបមុខរបរផ្ទាល់ខ្លួន ដែលកន្លងមកតែងប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ ដែលមានចំណាយខ្ពស់ និងមិនមានសុវត្ថិភាព។ ការប្រើប្រាស់សេវាទំនើបក៏អាចនាំមកនូវហានិភ័យមួយចំនួនដូចជាការបន្លំយូអរកូត និងការលួចអត្តសញ្ញាណបន្លំធ្វើជាជនរងគ្រោះដើម្បីលួចយកប្រាក់ក្នុងគណនី ឬព័ត៌មានសំខាន់ៗ។ ហេតុដូច្នេះសូមឱ្យមន្ត្រីបុគ្គលិកយើង ប្រុងប្រយ័ត្ននៅពេលបង់ប្រាក់ឬទូទាត់ សូមមើលឈ្មោះគណនីនិងចំនួនទឹកប្រាក់ឱ្យបានច្បាស់លាស់ ព្រមទាំងរក្សាលេខសម្ងាត់ឱ្យបានត្រឹមត្រូវ។

ស្របតាមការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានពង្រឹងជាប្រចាំនូវអភិបាលកិច្ច និងការអភិវឌ្ឍធនធានមនុស្សទាំងចំណេះនិងជំនាញតាមរយៈការផ្តល់ឱកាសឱ្យមានការបន្តការសិក្សាទាំងក្នុងនិងក្រៅប្រទេស ការសិក្សាតាមប្រព័ន្ធអនឡាញ ការផ្លាស់ប្តូរតួនាទីនិងភារកិច្ចដើម្បីឱ្យទទួលបានចំណេះដឹងនិងបទពិសោធន៍

ជាក់ស្តែងបន្ថែម ជាមួយនឹងការបង្កើតអគ្គនាយកដ្ឋាននិងនាយកដ្ឋានកាន់តែចំជំនាញក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពការងារ។ សូមបញ្ជាក់ថា ធនាគារជាតិនៃកម្ពុជាបានផ្តល់អាហារូបករណ៍សម្រាប់វគ្គបណ្តុះបណ្តាលអនឡាញមួយចំនួន ដល់មន្ត្រីបុគ្គលិកយើងដែលមានចំណាប់អារម្មណ៍សិក្សាស្វែងយល់បន្ថែម ដើម្បីពង្រឹងសមត្ថភាពទៅតាមជំនាញរៀងៗខ្លួន។ ដូច្នេះ សូមឱ្យមន្ត្រីបុគ្គលិកយើង ស្វែងយល់បន្ថែមនូវព័ត៌មានអំពីអាហារូបករណ៍សម្រាប់វគ្គបណ្តុះបណ្តាលអនឡាញនានាជាមួយនាយកដ្ឋានបុគ្គលិក។

លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សលើជំនាញបច្ចេកទេសធនាគារ ដោយបច្ចុប្បន្ននេះ វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ដែលទើបតែផ្លាស់ប្តូរពីមណ្ឌលសិក្សាបច្ចេកទេសធនាគារ បានចាប់ផ្តើមផ្តល់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញធនាគារ ជាមួយនឹងទិសដៅបង្កើតថ្នាក់អនុបណ្ឌិត និងបណ្ឌិតនាពេលអនាគត។ ម៉្យាងទៀត ការរួមចំណែកផ្តល់ចំណេះដឹងហិរញ្ញវត្ថុនិងសេដ្ឋកិច្ចដល់សាធារណជនក៏បានកើនឡើងយ៉ាងឆាប់រហ័ស ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនអ្នកទស្សនានៅសារមន្ទីរព្រះស្រីលក្សានវរ្ម័ន និងអ្នកចូលរួមកម្មវិធីខ្ញុំស្រឡាញ់ប្រាក់រៀល ដែលមានការទាក់ទាញអ្នកចូលរួមកាន់តែច្រើនឡើងជារៀងរាល់ឆ្នាំនៅតាមបណ្តាខេត្ត។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកក្នុងការវិនិយោគលើសញ្ញាបណ្ណបៃតង និងគាំទ្រលើគោលការណ៍ឥណទានប្រកបដោយចីរភាពកម្ពុជារបស់សមាគមធនាគារនៅកម្ពុជា ដើម្បីរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នពុល ដោយសារការប្រែប្រួលអាកាសធាតុគឺជាការប្រឈមមួយខ្លាំងសម្រាប់ប្រទេសកម្ពុជានិងពិភពលោក។ បច្ចុប្បន្នធនាគារជាតិនៃកម្ពុជាក៏កំពុងរៀបចំផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុបៃតងនៅកម្ពុជា ប្រព័ន្ធវដ្តករសាស្ត្រ និងទីផ្សារហិរញ្ញវត្ថុបៃតងនៅកម្ពុជា ដើម្បីលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព អភិវឌ្ឍសេដ្ឋកិច្ចបៃតង និងទាក់ទាញការវិនិយោគលើវិស័យពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង ក៏ដូចជាគាំទ្រគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍបៃតងរបស់រាជរដ្ឋាភិបាលឆ្នាំ២០១៣-២០៣០ សំដៅរួមចំណែកដល់ការកាត់បន្ថយហានិភ័យពីការប្រែប្រួលអាកាសធាតុ។

ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តពង្រឹងការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការបង្កើនការយល់ដឹងនិងបំពេញកាតព្វកិច្ចរបស់បុគ្គលរាយការណ៍ ការវិភាគ ការត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ។ ទន្ទឹមនេះ ក្របខ័ណ្ឌ និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិ ត្រូវបានពង្រឹងជាប្រចាំស្របតាមស្តង់ដាអន្តរជាតិ និងការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា ដើម្បីទប់ស្កាត់បទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

លទ្ធផលល្អប្រសើរទាំងអស់ខាងលើនេះ ត្រូវបានបន្តសម្រេចឡើងដោយឈរលើមូលដ្ឋានរឹងមាំនៃប្រព័ន្ធធនាគារ ដែល ឯកឧត្តម ជា ចាន់តូ អតីតទេសាភិបាល ធនាគារជាតិ

នៃកម្ពុជា បានកសាងឡើងក្រោមម្លប់សន្តិភាពពេញលេញដែលធានាបានដោយរាជរដ្ឋាភិបាល ក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមកនេះ។ ការគាំទ្ររបស់រាជរដ្ឋាភិបាលលើការអនុវត្ត គោលនយោបាយនានារបស់ធនាគារជាតិនៃកម្ពុជា ការអនុម័តនិងគាំទ្រលើទិសដៅការងារ ពីសំណាក់ក្រុមប្រឹក្សាភិបាល កិច្ចខិតខំប្រឹងប្រែងដោយទទួលខុសត្រូវរបស់មន្ត្រី-បុគ្គលិក គ្រប់លំដាប់ថ្នាក់ និងកិច្ចសហការរបស់ដៃគូភាគីពាក់ព័ន្ធទាំងអស់គឺជាផ្នែកដ៏សំខាន់ ដែលបានរួមចំណែកសម្រេចលទ្ធផលល្អជាទីមោទនៈនាឆ្នាំ២០២៤នេះ។

ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមជម្រាបជូនថា សៀវភៅទិនានុលេខន៍ថ្មី ដែលធនាគារជាតិ នៃកម្ពុជាផ្តល់ជូនឆ្នាំនេះ គឺប្លែកពីឆ្នាំមុនៗ ដែលយើងមានរៀបចំជាពិសេសដោយមាន គម្របសៀវភៅធ្វើពីស្បែក ហើយមានបោះឈ្មោះបុគ្គលិកនីមួយៗនៅលើគម្របនេះ។ ហេតុដូចនេះ នាឆ្នាំក្រោយៗទៅ យើងលែងចែកសៀវភៅថ្មីទៀតហើយ ដោយយើងនឹង ផ្តល់ជូនជាបណ្តូលសៀវភៅ ដែលមន្ត្រីបុគ្គលិកយើងអាចប្តូរបានសម្រាប់ឆ្នាំបន្ទាប់ៗទៀត ហើយយើងក៏មានចែកជូននូវកែវទឹកនិងថង់ក្រណាត់ដែលមានរូបធនាគារជាតិនៃកម្ពុជា ផងដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ដើម្បីជ្រាបពីសមិទ្ធផលលម្អិតដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅ ការងារចម្បងៗ ខ្ញុំសូមឱ្យអង្គសន្និបាតត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតជាបន្តបន្ទាប់ពេញមួយថ្ងៃនេះ។

ខ្ញុំសូមជូនពរឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យនិងផ្លែផ្កា។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**